សំរាប់ផ្សព្វផ្សាយបន្ទាន់: កិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្តីអំពីកម្ពុជា

# កម្ពុជា: រដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ មើលឃើញឱកាសទទួលបានអត្ថប្រយោជន៍ពីកំណែទំរង់ ដែលមានលក្ខណៈកាន់តែស៊ីជំរៅ នាពេលបច្ចុប្បន្ន

*កិច្ចប្រជុំរួមនេះបានបញ្ចប់ ដោយបានព្រមព្រៀងគ្នាលើកិច្ចព្រមព្រៀងថ្មីស្តីអំពីដំណាក់កាល បន្ទាប់សំរាប់ធ្វើអោយអនាគតកាន់តែប្រសើរឡើង*

ទំនាក់ទំនង: នៅភ្នំពេញ: លោក ប៊ូ សារឿន : ៨៥៥-២៣-២១៧៣-០១
sbou@worldbank.org
នៅទីក្រុងបាងកក: Kimberly Versak :៦៦-១-៨៧៥-៥០៦៤
kversak@worldbank.org

**ភ្នំពេញ ថ្ងៃទី ៣ ខែ មិនា ឆ្នាំ ២០០៦** _កិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី ៨ ស្តីអំពីប្រទេសកម្ពុជា បានបញ្ចប់នៅថ្ងៃនេះ នៅទីក្រុងភ្នំពេញ ដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាច្រើនបានឯកភាពជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានថ្លែងនៅក្នុងសុន្ទរកថារបស់សម្តេចថា ប្រទេសកម្ពុជា បានជ្រើសរើស *"ផ្លូវមួយយ៉ាងល្អឆ្ពោះទៅរកការរីកចំរើន និងការទទួលស្គាល់សក្តានុពលពិតប្រាកដរបស់ខ្លួន"* ក៏ប៉ុន្តែ ថា *"រាល់ដំណាក់កាលនិមួយៗបង្ហាញយើងអំពីបញ្ហាប្រឈមថ្មីៗនៅពេលខាងមុខ"* ។ សំរាប់ប្រទេសកម្ពុជា ដើម្បីទទួលអត្ថប្រយោជន៍ ពីឱកាសដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងទសវត្សរ៍បន្ទាប់ទៀត គណៈប្រតិភូជាច្រើនបានឯកភាពគ្នាថា កម្ពុជាចាំបាច់ត្រូវតែចាប់ផ្តើមក្នុងពេលឥឡូវនេះ ដើម្បីច្របាច់បញ្ចូលគ្នានូវការរីកចំរើនដែលសំរេចបានកន្លងមករហូតមកដល់បច្ចុប្បន្ននេះ និងបង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទំរង់របស់ខ្លួន ដើម្បីដោះស្រាយបញ្ហាប្រឈមនានាដែលនៅសេសសល់ ។

គណៈប្រតិភូ បានឯកភាពគ្នាថា មានហេតុផលចំពោះភាពសុទិដ្ឋិនិយម –បើពិនិត្យទៅលើការរីកចំរើនក្នុងទសវត្សរ៍កន្លងទៅ និងការសំរេចបាននូវកំណើនសេដ្ឋកិច្ចនិងកំណែទំរង់ក្នុងឆ្នាំកន្លងទៅ ។ ក៏ប៉ុន្តែ ដើម្បីអោយការរីកចំរើនក្នុងរយៈពេលទសវត្សរ៍កន្លងទៅនៅតែបន្តប្រកបដោយចិរភាព តាមរយៈការឆ្លងកាត់ពីសង្គ្រាមមកសន្តិភាព រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា នឹងចាំបាច់ត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទ្វេដងថែមទៀត ដើម្បីអនុវត្តកំណែទំរង់ និងកែលំអប្រសិទ្ធិភាពជំនួយ ។

កិច្ចប្រឹងប្រែងទាំងនេះរួមមាន កំណែទំរង់ដើម្បីកាត់បន្ថយអំពើពុករលួយ និងធ្វើអោយរដ្ឋាភិបាលកាន់តែមានការឆ្លើយតប កាន់តែមានការទទួលខុសត្រូវ កាន់តែមានប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព បន្តប្តេជ្ញាធ្វើអោយមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើនកំណើនសេដ្ឋកិច្ចដែលកាន់តែមានលក្ខណៈទូលំទូលាយ និងកាន់តែប្រកបដោយសមធម៌ ធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងវិស័យឯកជនដែលនាំទៅដល់ការរីកចំរើនផ្នែកសេដ្ឋកិច្ច និងកែលំអសេវាកម្មសំរាប់ការអភិវឌ្ឍនធនធានមនុស្ស ព្រមទាំងកែលំអក៏រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ។ គណៈប្រតិភូបានឯកភាពគ្នាថា ចាំបាច់ត្រូវតែបន្តកិច្ចប្រឹងប្រែងដើម្បីបង្កើតនូវបរិយាកាសមួយដែលមានលក្ខណៈកាន់តែទូលំទូលាយ សំរាប់ពិភាក្សា និងផ្លាស់ប្តូរយោបល់ និងផ្តល់អោយប្រជាពលរដ្ឋ ជាពិសេស ជនក្រីក្រ នូវឱកាសនិងមធ្យោបាយក្នុងការលើកឡើងនូវការព្រួយបារម្ភនានា និងស្នើសុំអោយមានការផ្លាស់ប្តូរ ដើម្បីអោយពួកគេអាចកែលំអទស្សនៈនៃកំណែទំរង់ប្រកបដោយជោគជ័យ ។

សម្តេចនាយករដ្ឋមន្ត្រី បានប្រកាសថា *"ដើម្បីសំរេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា (CMDGs) កម្ពុជា ចាំបាច់ត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមាន និងបញ្ហាប្រឈមនានាដែលកំពុងតែគំរាមកំហែង"* ។

កិច្ចប្រជុំក្រុមពិគ្រោះយោបល់នេះ ត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២-៣ ខែ មីនា នៅទីក្រុងភ្នំពេញ ដោយមានការចូលរួមពីតំណាងសហគមន៍ផ្តល់ជំនួយជាច្រើន រួមមាន: ប្រទេសជាដៃគូចំនួន ១២ ប្រទេសជាអ្នកសង្កេតការណ៍ចំនួន ៨ អង្គការអភិវឌ្ឍន៍អន្តរជាតិចំនួន ៥ និងរាជរដ្ឋាភិបាលកម្ពុជា។ តំណាងជាច្រើនរូបទៀតមកពីអង្គការសង្គមស៊ីវិល និងផ្នែកឯកជន ក៏បានចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។

## *សារិតារបស់ប្រទេស : សមិទ្ធិផលរបស់ប្រទេសកម្ពុជា*

សម្តេចនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់អំពីការទទួលបាននូវសន្តិភាព និងស្ថេរភាពក្នុងទសវត្សរ៍កន្លងទៅ ក្នុងការកែលំអកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបង្ហាញអំពីឱកាសដ៏ច្រើន។ សម្តេច បានថ្លែងថា *"កម្ពុជា បានចាកចេញពីសង្គ្រាមឆ្ពោះទៅរកសន្តិភាព ពីវិប្បធម៌ទំនាស់ទៅវិប្បធម៌សំរបសំរួល និងពីវិប្បធម៌ប្រឈមមុខដាក់គ្នាទៅជាវិប្បធម៌ចរចា និងផ្សះផ្សារ។ នៅពេល ដែលយើងធ្វើដំណើរឆ្ពោះទៅកាន់សតវត្សរ៍ទី២១ រយៈពេល ១០ឆ្នាំខាងមុខ គឺជាទសវត្សរ៍នៃកាលានុវត្តភាពមួយ ដើម្បីសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍របស់យើង (ដូចដែលបានកំណត់ក្នុង CMDGs) និងគាំទ្រដល់ជនក្រីក្រនិងជនងាយទទួលរងគ្រោះ"* ។ ទាក់ទងទៅនឹងការវិវត្តិរីកចំរើនសំខាន់ៗដែលសំរេចបានតាមរយៈការបង្កើតផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំថ្មីរបស់រដ្ឋាភិបាល គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងការងារទាក់ទងផ្សេងទៀតដែលទាក់ទងនឹងផែនការនេះដែលកំណត់នូវចំណាយអាទិភាពរបស់រដ្ឋាភិបាល កម្មវិធីវិនិយោគសាធារណៈ (PIP) សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា *"ការដាក់ចេញនូវយុទ្ធសាស្ត្រនិងគោលដៅនានានៅលើក្រដាស គឺជាជំហានទីមួយ។ ពិសេសជាងនេះ គឺការធ្វើផែនការនិងបន្តអនុវត្តដាក់ស្តែងដើម្បីសំរេចអោយបានគោលដៅទាំងអស់នេះ...យើងចាំបាច់ត្រូវតែខិតខំប្រឹងប្រែងបំពេញការងារបន្ថែមទៀតដើម្បីបន្តកែលំអអភិបាលកិច្ច ប្រសិនបើយើងចង់កាត់បន្ថយភាពក្រីក្រអោយបានកាន់តែច្រើនជាងនេះ"* ។

គណៈប្រតិភូបានស្វាគមន៍ចំពោះ NSDP និង PIP ដោយចាត់ទុកថាជាសញ្ញាណដ៏សំខាន់មួយរបស់រដ្ឋាភិបាលក្នុងភាពជាម្ចាស់លើរបៀបវារៈអភិវឌ្ឍន៍ និងបានកោតសរសើរដល់វិធីសាស្ត្ររបស់ NSDP ក្នុងការផ្តល់នូវផែនទីផ្លូវ ការកំណត់អាទិភាព និងតំរូវការធនធាន សំរាប់ជួយដល់រដ្ឋាភិបាលក្នុងការសំរេចអោយបាននូវទស្សនៈវិស័យរបស់ខ្លួនដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដោយសារផែនការផ្តោតលើវិស័យដែលមានលក្ខណៈពិស្តារសំរាប់ NSDP ត្រូវបានអភិវឌ្ឍនិងអនុវត្ត គណៈប្រតិភូបានឯកភាពដើម្បីធ្វើការរួមគ្នាដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនប្រភពផ្សេងៗនៃកំណើន បង្កើនការគ្រប់គ្រងដីធ្លីអោយកាន់តែប្រសើរឡើង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងធ្វើការវិនិយោគលើការអភិវឌ្ឍធនធានមនុស្សជាមូលដ្ឋាន ដើម្បីបង្កើនឥទ្ធិពលនិងប្រសិទ្ធិភាពរបស់ផែនការ៥ឆ្នាំនេះ។ រាជរដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយ បានឯកភាពដើម្បីធ្វើការតំរែតំរង់រៀបចំធនធានសាធារណៈទាំងអស់អោយបានប្រសើរឡើង រួមទាំងជំនួយសំរាប់ NSDP និង PIP ផងដែរ។

គណៈប្រតិភូបានឯកភាពគ្នាថា ចាប់តាំងពីកិច្ចប្រជុំក្រុមពិគ្រោះយោបល់ចុងក្រោយក្នុងខែធ្នូ ឆ្នាំ ២០០៤ មក មានការរីកចំរើនគួរអោយកត់សំគាល់មួយចំនួន (កំណើននៅរក្សាបានក្នុងកំរិតជាមធ្យម ៧ភាគរយ ក្នុងមួយឆ្នាំ ទោះបីជាតំលៃប្រេងឥន្ធនៈកើនឡើងខ្ពស់ និងការបញ្ចប់កិច្ចព្រមព្រៀងពហុវាយណភណ្ឌ (MFA)ក៏ដោយ) និងសូចនាករសេដ្ឋកិច្ចនិងសង្គមផ្សេងទៀតក៏មានការកើនឡើងផងដែរ រួម

ទាំងការកាត់បន្ថយអត្រាស្លាប់របស់កុមារនិងមាតា ការថយចុះគួរអោយកត់សំគាល់នៃជំងឺឆ្លង និងកែលំអសេវាផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់ទីក្រុង។ ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ក៏ទទួលបានលទ្ធផលមួយចំនួនផងដែរ តាមរបាយការណ៍វាយតំលៃលើភាពក្រីក្រ ដែលបានចេញផ្សាយកាលពីសប្តាហ៍មុន បង្ហាញថា អត្រានៃភាពក្រីក្របានថយចុះពីប្រមាណ ៤៧ភាគរយ នៅក្នុងឆ្នាំ ១៩៩៣-៩៤ មកនៅ ៣៥ ភាគរយនៅក្នុងឆ្នាំ ២០០៤។ លោក អៀន ផតធ័រ នាយកធនាគារពិភពលោកប្រចាំនៅកម្ពុជា និងជាសហប្រធានក្នុងកិច្ចប្រជុំនេះ បានមានប្រសាសន៏ថា *"ជាចុងក្រោយ លទ្ធផលទាំងនេះ បានបង្ហាញនូវទស្សនៈដែលបានធ្វើកន្លងមកដែលថា កម្ពុជាបានទទួលនូវទសវត្សរ៍នៃកំណើនដ៏ប្រសើរមួយ ជាមួយនឹងឥទ្ធិពលតិចតួច ឬក៏គ្មានសោះក្នុងការកាត់បន្ថយភាពក្រីក្រ"* ។

លោក បានបន្តទៀតថា *"ក៏ប៉ុន្តែ វាជារឿងមួយដ៏សំខាន់ដែលត្រូវចងចាំថា ទោះបីជាមានកំណើននិងស្ថេរភាព បានជួយកាត់បន្ថយភាពក្រីក្រក៏ពិតមែន តែសេដ្ឋកិច្ចនៅតែពឹងផ្អែកទាំងស្រុងទៅលើវិស័យមួយចំនួនតូច និងអត្ថប្រយោជន៏ជាចំបងនៃកំណើននេះ ត្រូវបានផ្តោតយ៉ាងខ្លាំងទៅលើពួកអ្នកមានមួយក្រុមនៅក្នុងទីក្រុង ដែលជាហេតុនាំអោយវិសមភាពរវាងអ្នកមាននិងអ្នកក្រមានការកើនឡើងយ៉ាងលឿន"* ។

ឯកឧត្តម គាត ឈុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសហប្រធានក្នុងកិច្ចប្រជុំនេះ បានមានប្រសាសន៏ថា *"ទោះបីជាមានការរីកចំរើនគួរអោយកត់សំគាល់ក៏ដោយ យើងនៅតែជួបប្រទះបញ្ហាប្រឈមជាច្រើន ក្នុងការប្រយុទ្ធប្រឆាំនឹងភាពក្រីក្រ។ ការកែលំអករិជីវភាពរស់នៅ និងការបែងចែកកំណើនប្រកបដោយសមធម៌ក្នុងចំណោមប្រជាជនទាំងអស់ នៅតែជាអាទិភាពសំខាន់មួយរបស់រាជរដ្ឋាភិបាល។ វិស័យកសិកម្ម គឺជាប្រភពនៃការលើកកំពស់ក៏រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលតំណាងអោយកំលាំងពលកម្មច្រើនជាង ៧០ ភាគរយ។ ដូច្នេះ ការបង្កើនការអភិវឌ្ឍលើវិស័យនេះ គឺជាអាទិភាពខ្ពស់បំផុតនិងជាបន្ទាន់។ ការអភិវឌ្ឍដែលប្រកបដោយចិរភាព ការកាត់បន្ថយភាពក្រីក្រ និង CMDGs នឹងមិនអាចសំរេចបានទេ ប្រសិនបើគ្មានការកែលំអជាដុំកំភួនបន្ថែមទៀតលើផលិតភាពដំណាំស្រូវ និងការបង្កើនដំណាំអោយបានច្រើនប្រភេទ ព្រមទាំងជំរុញការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម"* ។

ក៏មានការរីកចំរើនលើផ្នែកកំណែទំរង់ស្ថាប័ននិងគោលនយោបាយមួយចំនួនផងដែរ (ដែលត្រូវបានវាស់វែងតាមរយៈសូចនាករត្រួតពិនិត្យរួម ឬហៅកាត់ថា JMIs) ជាមួយនឹងគំនិតផ្តួចផ្តើមនានាក្នុងការបង្កើតនិងអនុម័តយុទ្ធសាស្ត្រ និងក្នុងការអនុវត្តនូវសកម្មភាពជាក់លាក់នានា នៅក្នុងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យឯកជន ការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធដែលបានធ្វើឡើងក្នុងរយៈពេល ១៥ ខែកន្លងទៅ។ ប្រទេសផ្តល់ជំនួយបានកត់សំគាល់ថា កំណែទំរង់រដ្ឋបាលសាធារណៈ និងសុខដុមណីយកម្ម និងសង្គតិភាពនៃជំនួយ ក៏ត្រូវបានអភិវឌ្ឍផងដែរ។ លោក ផតធ័រ បានថ្លែងនៅក្នុងសុន្ទរកថាបិទកិច្ចប្រជុំក្នុងថ្ងៃនេះថា *"នៅពេលដែលយើងប្រៀបធៀប អត្រារីកចំរើនពីឆ្នាំ ២០០៤ ដល់ ២០០៦ ទៅនឹងកិច្ចប្រជុំ CG កន្លងទៅ ក្នុងរយៈពេលពីឆ្នាំ ២០០២ ដល់ ២០០៤ យើងកត់សំគាល់ឃើញថា មានការរីកចំរើនយ៉ាងច្បាស់លើកំណែទំរង់ក្នុងវិស័យភាគច្រើន។ នៅក្នុងផ្នែកទាំងនេះ ចលករមួយត្រូវបានបង្កើតឡើងដែលកំពុងតែមានលក្ខណះប្រសើរ។ ហើយទោះបីជាកំណត់សំគាល់នេះនៅមានភាពលោយឡំគ្នាក៏ដោយ ក៏គេយល់ថា កម្ពុជាកំពុងតែដើរតាមផ្លូវដ៏ត្រឹមត្រូវមួយដែរ"* ។

### *សំលឹងមើលទៅអនាគត : បញ្ហាប្រឈមធ្ងន់ធ្ងរនៅតែកើតមាន*

គណៈប្រតិភូបានសង្កត់ធ្ងន់ថា ចាំបាច់ត្រូវតែបង្កើនការធ្វើកំណែទំរង់សំខាន់ៗលើការគ្រប់គ្រងធនធានធម្មជាតិ លើក្របខ័ណ្ឌច្បាប់និងតុលាការ និងលើការប្រឆាំងនឹងអំពើពុករលួយ ចាំបាច់ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីសំរេចអោយបាននូវសមិទ្ធិផលសំខាន់ៗ ដែលមាន

ឥទ្ធិពលភ្លាមៗ ទាក់ទងទៅនឹងការតំរង់ផ្លូវដល់រដ្ឋាភិបាលក្នុងការធ្វើកំណែទំរង់ និងទាក់ទងទៅនឹងអត្ថប្រយោជន៍រយៈពេលវែងបន្ថែមទៀត ក្នុងការបង្កើនភាពជឿជាក់នៅក្នុងប្រទេស បង្កើនកំណើនសេដ្ឋកិច្ច និងជាចុងក្រោយបង្កើនការកាត់បន្ថយភាពក្រីក្រ។

គណៈប្រតិភូ បានអំពាវនាវអោយបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងភាពអន់ខ្សោយក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ គណៈប្រតិភូ បានកត់សំគាល់ថា នៅពេលដែលមានព័ត៌មានកាន់តែច្រើនឡើងស្តីអំពីសម្បទានដីសេដ្ឋកិច្ច គេចាំបាច់ត្រូវតែបង្កើនការផ្សព្វផ្សាយអោយកាន់តែច្រើនឡើង ដើម្បីបង្កើនតម្លាភាពនិងប្រសិទ្ធិភាពខ្ពស់។ គណៈប្រតិភូ បានស្វាគមន៍ការប្តេជ្ញាចិត្តរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានថ្លែងថា ដីដែលមិនត្រូវបានប្រើប្រាស់ដោយសមស្រប ត្រូវផ្លាស់ប្តូរពីសម្បទានដីសេដ្ឋកិច្ច អោយទៅជាសម្បទានដីសង្គមកិច្ច សំរាប់ប្រជាពលរដ្ឋក្រីក្រ ហើយក៏បានបង្កើនការយកចិត្តទុកដាក់បន្ថែម ដើម្បីធានាដោះស្រាយជំលោះដីធ្លីអោយបានត្រឹមត្រូវនិងប្រកបដោយសមធម៌ ពីព្រោះភាពមិនច្បាស់លាស់ក្នុងការកាន់កាប់ដីធ្លី នៅតែជាឧបសគ្គដ៏ចំបងមួយចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជា និងជាកត្តាសំខាន់មួយក្នុងការធ្វើអោយវិសមភាពក្នុងសង្គមកើនឡើង។ គណៈប្រតិភូ ក៏បានឯកភាពជាមួយការអំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលសុំអោយបន្តធ្វើការពិនិត្យតាមដានឧក្រិដ្ឋកម្មព្រៃឈើដោយឯករាជ្យ (ដែលទាមទារនូវការគាំទ្រផ្នែកមូលនិធិពីប្រទេសផ្តល់ជំនួយ) ហើយគណៈប្រតិភូ បានកត់សំគាល់ថា ក្របខ័ណ្ឌស្ថាប័នសំរាប់ពិនិត្យតាមដានដែលមានលក្ខណៈឯករាជ្យលើការកាប់ឈើខុសច្បាប់ និងការដណ្តើមដីធ្លី ចាំបាច់ត្រូវតែធ្វើការពិនិត្យមើលសាឡើងវិញជាបន្ទាន់។ គេក៏ត្រូវការចាំបាច់ផងដែរនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលមានលក្ខណៈទូលំទូលាយមួយ ដើម្បីដឹកនាំការធ្វើកំណែទំរង់ និងការងារអភិវឌ្ឍ នៅក្នុងផ្នែកដ៏សំខាន់នេះ ដែលអាចផ្តល់នូវអត្ថប្រយោជន៍ដ៏ច្រើនសន្ធឹកដល់ប្រជាពលរដ្ឋក្រីក្ររស់នៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជា។

*អំពីផ្នែកកំណែទំរង់ច្បាប់និងតុលាការ* អ្នកចូលរួមជាច្រើន បានជំរុញអោយរដ្ឋាភិបាលបន្តធ្វើការសំរេចចិត្តក្នុងការអនុម័តច្បាប់ចំនួន ៨ ដែលជាមូលដ្ឋានគ្រឹះសំរាប់បង្កើតនូវក្របខ័ណ្ឌដ៏ល្អមួយសំរាប់ប្រព័ន្ធច្បាប់និងតុលាការអោយកាន់តែមានប្រសិទ្ធិភាពជាងមុន។ *អំពីការប្រឆាំងនឹងអំពើពុករលួយ* គណៈប្រតិភូ បានកត់សំគាលថា ច្បាប់ពង្រាងបច្ចុប្បន្ន ដែលបានបង្ហាញថាមានការកែលំអគួរអោយកត់សំគាល់នោះ នៅតែមិនទាន់ឆ្លើយតបទៅតាមប្រព័ន្ធច្បាប់ជាលក្ខណៈអន្តរជាតិនៅឡើយទេ ហើយគណៈប្រតិភូបានអំពាវនាវអោយចាត់វិធានការជាក់លាក់ចំនួន ៤ ដើម្បីបំពេញនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងកិច្ចប្រជុំ CG ចុងក្រោយ : ឯករាជ្យភាពនៃប្រតិបតិការនិងថវិការបស់អង្គការប្រឆាំងនឹងអំពើពុករលួយ (ACB) នឹងត្រូវបង្កើតឡើង ការត្រួតពិនិត្យប្រតិបត្តិការដោយអគ្គលេខាធិការលើក្រុមអ្នកស៊ើបអង្កេតរបស់ ACB សិទ្ធិឬឱកាសទទួលបាននូវឯកសារប្រកាសទ្រព្យសម្បត្តិដោយអគ្គលេខាធិការ និងសុខដុមណីយកម្មនៃបទល្មើសព្រហ្មទណ្ឌជាមួយនឹងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីអំពីការប្រឆាំងនឹងអំពើពុករលួយ (UNCAC) និងពង្រាងច្បាប់ព្រហ្មទណ្ឌនិងច្បាប់នីតិវិធីព្រហ្មទណ្ឌ។ រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពក្នុងការពិនិត្យពិចារណាលើបញ្ហានានាដែលបានលើកឡើង និងបានគូសបញ្ជាក់អំពីតំរូវការអោយមានវិធីសាស្ត្រមួយដែលមានលក្ខណៈទូលំទូលាយ និងកសាងសមត្ថភាពសំរាប់ការអនុវត្ត។

ក្នុងកិច្ចពិភាក្សាអំពី JMIs សំរាប់ឆ្នាំក្រោយ គណៈប្រតិភូ បានកត់សំគាល់ថា ទំនាក់ទំនងជិតស្និទ្ធិរវាង JMIs និងអាទិភាពនៃកំណែទំរង់ដែលបានដាក់ចេញនៅក្នុង NSDP។ ក្រៅអំពី JMIs ស្តីអំពីបញ្ហានានាដែលបានលើកឡើងពីខាងលើ (ការគ្រប់គ្រងធនធានធម្មជាតិ កំណែទំរង់ច្បាប់និងតុលាការ និងការប្រឆាំងនឹងអំពើពុករលួយ) JMIs មួយចំនួន បានឯកភាពសំរាប់ឆ្នាំក្រោយ ដើម្បីបន្តដំណើរការកែទំរង់ដែល

កំពុងតែប្រព្រឹត្តទៅ រួមមាន ៖ ការបន្តធ្វើកំណែទំរង់រដ្ឋបាលសាធារណៈ ដោយផ្តោតការយកចិត្តទុកដាក់លើរាជការស៊ីវិល ធ្វើកំណែទំរង់បន្ថែមទៀតលើវិមជ្ឈការនិងវិសហមជ្ឈការ ដំណាក់កាលកែលំអការផ្តត់ផ្គង់សេវា ព្រមទាំងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍធនធានមនុស្ស តាមរយៈ JMIs ស្តីអំពីច្បាប់អំពើហឹង្សាក្នុងគ្រួសារ និងការផ្តល់អំណាចដល់ស្ត្រី និងវិធានការទប់ស្កាត់ជំងឺហ៊ីវ/អេដស៍ និងការជួញដូរគ្រឿងញៀន។ អំពីការអភិវឌ្ឍវិស័យឯកជន គណៈប្រតិភូ បានឯកភាពថា ចាំបាច់ត្រូវតែពង្រឹងកិច្ចសំរបសំរួលពាណិជ្ជកម្ម និងកិច្ចប្រឹងប្រែងដើម្បីអភិវឌ្ឍទីផ្សារ និងបង្កើនតម្លាភាព និងគណនេយ្យភាព។ JMIs ដែលផ្តោតការយកចិត្តទុកដាក់ទៅលើហេដ្ឋារចនាសម្ព័ន្ធកំណើនដែលដឹកនាំដោយវិស័យឯកជន និងការបង្កើនប្រសិទ្ធិភាពជំនួយ ក៏ត្រូវបានលើកយកមកពិភាក្សា និងបានឯកភាពគ្នាផងដែរ។

លោក ផតធ័រ បានធ្វើអត្ថាធិប្បាយថា *"សូចនាករពិនិត្យតាមដានរួមទាំងនេះ គឺជាជំហានមួយនៅក្នុងទិសដៅដែលត្រឹមត្រូវ ឆ្ពោះទៅរកការពង្រឹងភាពជាដៃគូសំរាប់ធ្វើកំណែទំរង់ និងឆ្ពោះទៅរកគោលដៅរួមដើម្បីពង្រឹងប្រព័ន្ធគណនេយ្យភាពនៅក្នុងប្រទេសកម្ពុជា។ នៅពេលដែលការរីកចំរើនមានភាពខ្វះ សូចនាករទាំងនេះមានលក្ខណៈគួរអោយកត់សំគាល់ ហើយយើងចាំបាច់ត្រូវតែយល់ថា នៅក្នុងបរិស្ថានអភិវឌ្ឍន៏មួយដែលមានលក្ខណៈស្មុគស្មាញបែបនេះ ការជំរុញរបៀបវារៈនេះអោយទៅមុខ នឹងត្រូវការនូវពេលវេលា។ កម្ពុជា ស្ថិតនៅក្នុងដំណាក់កាលសំខាន់មួយ - កម្ពុជាបានចាប់ផ្តើមធ្វើកំណែទំរង់ ក៏ប៉ុន្តែ បច្ចុប្បន្ននេះ ត្រូវអនុវត្តនូវសកម្មភាពចាំបាច់នានា ដើម្បីឈានឆ្ពោះទៅមុខអោយបានខ្លាំងក្លានៅក្នុងវិស័យសំខាន់ៗទាំងនេះ ដូចជា ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រឆាំងនឹងអំពើពុករលួយ និងនៅបន្តបង្ហាញ អំពីកំលាំងចលករ ការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយ នៅក្នុងផ្នែកកំណែទំរង់ទាំងអស់។ ជាការឆ្លើយតប ដៃគូអភិវឌ្ឍន៏នានា ត្រូវតែបន្តកិច្ចការងាររបស់ខ្លួនជាមួយនឹងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីជួយប្រទេសអោយសំរេចបាននូវទិសដៅអភិវឌ្ឍន៏របស់ខ្លួន ។ ទីបំផុត ធ្វើអោយជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់កាន់តែល្អប្រសើរឡើង"* ។

បញ្ជីលំអិតរបស់ JMIs ត្រូវបានគេឯកភាពដើម្បីផ្សព្វផ្សាយជាសាធារណៈក្នុងពេលឆាប់ៗនេះ តាមរយៈវេបសាយ ៖ www.cdc-crdb.gov.kh និង www.worldbank.org/kh ។

ក្នុងកិច្ចពិភាក្សាអំពីប្រសិទ្ធិភាពជំនួយ គណៈប្រតិភូបានឯកភាពគ្នាថា កម្ពុជាមានការរីកចំរើនគួរអោយកត់សំគាល់ក្នុងការបង្កើតនូវគោលការណ៏ផ្សេងៗ និងផែនការសកម្មភាពមួយសំរាប់សុខដុមណីយកម្មនិងសង្គតិភាព បន្ទាប់ពីសេចក្តីប្រកាសទីក្រុងប៉ារី ខែ មីនា ឆ្នាំ ២០០៥ ក៏ប៉ុន្តែ ឥឡូវនេះ គេត្រូវតែចាត់វិធានការដ៏ហ្មត់ចត់ដើម្បីអនុវត្តផែនការនេះ។ គណៈប្រតិភូ បានឯកភាពគ្នាថា ក្រុមការងារបច្ចេកទេសផ្សេងៗ (ដែលជាផ្នែកសំខាន់ជាមូលដ្ឋានសំរាប់សុខដុមណីយកម្មនិងសង្គតិភាព) នឹងត្រូវបានធ្វើការវាយតំលៃសាជាថ្មី និងត្រូវបានពង្រឹងដោយបង្កើនឱកាសសំរាប់ការពិភាក្សានិងផ្លាស់ប្តូរយោបល់លើគោលនយោបាយ រវាងភាគីពាក់ព័ន្ធផ្សេងៗដែលបានបង្កើតឡើង។ គណៈប្រតិភូ ក៏បានឯកភាពជាមួយនឹងរដ្ឋាភិបាលផងដែរ ទៅលើសំណើរបស់រដ្ឋាភិបាលក្នុងគោលបំណងដើម្បីអភិវឌ្ឍនិងអនុវត្តកម្មវិធីគ្របដណ្តប់លើវិស័យអោយបានកាន់តែច្រើនថែមទៀត និងឈានទៅសំរេចកិច្ចព្រមព្រៀងដែលមានលក្ខណៈទូលំទូលាយមួយក្នុងការដោះស្រាយបញ្ហាលំបាកនានា ដូចជា ការលប់បំបាត់ចោលនូវប្រាក់បៀវត្សរ៏បន្ថែម និងតួនាទីរបស់ជំនួយបច្ចេកទេស ក្នុងការកសាងសមត្ថភាពពិតប្រាកដផ្ទាល់របស់របស់កម្ពុជា។

វិធានការក្នុងការបញ្ចូលបន្ថែមនូវរបៀបវារៈនៃសុខដុមណីយកម្មនិងសង្គតិភាព ចាំបាច់ត្រូវតែចាប់ផ្តើមអនុវត្ត (ដែលសំដៅពង្រីកទំហំ និងបង្កើនភាពស៊ីជំរៅនៃភាពជាម្ចាស់របស់ប្រទេសលើរបៀបវារៈអភិវឌ្ឍន៏) ដោយរួមបញ្ចូលទាំងដៃគូរដ្ឋ និងដៃគូមិនមែនរដ្ឋ។

រដ្ឋាភិបាល បានស្វាគមន៍ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ស្តីអំពីការអភិវឌ្ឍរួមនិងប្រកបដោយការទទួលខុសត្រូវខ្ពស់។ គណៈប្រតិភូ បានឯកភាពគ្នាថា ឥឡូវនេះ គឺជាឱកាសដ៏ល្អមួយ ដើម្បីបង្កើតនូវការស្រុះស្រួលមតិគ្នាអោយបានកាន់តែខ្លាំងក្លា រវាងរាជរដ្ឋាភិបាល សង្គមស៊ីវិលកម្ពុជា វិស័យឯកជនជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស លើអាទិភាពនានាសំរាប់អភិវឌ្ឍប្រទេសកម្ពុជា។ គណៈប្រតិភូ បានថ្លែងថា ការចូលរួមក្នុងកិច្ចពិភាក្សាស៊ីជំរៅនិងដែលមានលក្ខណៈស្ថាបនា នឹងជួយធ្វើអោយប្រសើរឡើងដល់ការផ្តោតការយកចិត្តទុកដាក់លើអាទិភាពទាំងនេះ និងកែលំអជីវភាពរស់នៅដែលជាលទ្ធផលសំរេចបានពីកិច្ចប្រឹងប្រែងអភិវឌ្ឍន៍នានា។ តំណាងមកពីសហគមន៍អង្គការក្រៅរដ្ឋាភិបាល បានស្វាគមន៍ចំពោះការបង្កើត **NSDP** និងឱកាសចូលរួមជាមួយរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ លើបញ្ហាមូលដ្ឋានទាំងនេះ។

ប្រទេសផ្តល់ជំនួយបានសន្យាផ្តល់ជំនួយចំនួន ៦០១ លានដុល្លារអាមេរិក សំរាប់គាំទ្រដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃផែនការថវិកានិងហិរញ្ញវត្ថុរបស់កម្ពុជា សំរាប់ឆ្នាំ ២០០៦។ កាលពីឆ្នាំ ២០០៤ ប្រទេសផ្តល់ជំនួយបានសន្យាផ្តល់ជំនួយចំនួន ៥០៤ លានដុល្លារអាមេរិក។ ក្រៅពីនេះ កម្ពុជាទទួលបានការលប់ចោលនូវបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ចំនួន ៨២ លានដុល្លារអាមេរិក ដោយសារតែកម្ពុជា បានបំពេញនូវលក្ខខណ្ឌសំខាន់ៗចំនួន ៣ គឺ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច កម្មវិធីកាត់បន្ថយភាពក្រីក្រ និងការអនុម័តនូវរបៀបវារៈកំណែទំរង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល បានឯកភាពគ្នា ប្រារព្ធកិច្ចប្រជុំប្រចាំឆ្នាំនេះ សំរាប់ឆ្នាំក្រោយម្តងទៀត នៅខែមិថុនា ឆ្នាំ ២០០៧ នៅទីក្រុងភ្នំពេញ។

សំរាប់ព័ត៌មានបន្ថែមស្តីអំពីកិច្ចប្រជុំក្រុមពិគ្រោះយោបល់នេះ សូមភ្ជាប់ទៅវេបសាយនេះ www.cdc-crdb.gov.kh or www.worldbank.org/kh.

---

*កិច្ចប្រជុំក្រុមពិគ្រោះយោបល់នេះ ត្រូវបានរៀបចំទទួលដោយរដ្ឋាភិបាលកម្ពុជា នៅទីក្រុងភ្នំពេញ នៅថ្ងៃទី ២-៣ ខែ មីនា ឆ្នាំ ២០០៦ ដោយមានការចូលរួមពីគណៈប្រតិភូជាច្រើនមកពីប្រទេសចំនួន ១៨ និងអង្គការអន្តរជាតិចំនួន ៥។ ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាប្រធានគណៈប្រតិភូកម្ពុជា និងលោក អៀន ផតផ័រ នាយកធនាគារពិភពលោកប្រចាំនៅកម្ពុជា បានធ្វើជាសហប្រធានក្នុងកិច្ចប្រជុំនេះ។ ចំនួនប្រទេសនិងអង្គការដែលបានចូលរួមក្នុងកិច្ចប្រជុំនេះមាន : ប្រទេសអូស្ត្រាលី កាណាដា ដេនម៉ាក ហ្វាំងឡង់ បារាំង អាឡឺម៉ង់ ជប៉ុន សាធារណរដ្ឋកូរ៉េ ញូស៊ីឡែន ស៊ុយអែត ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក។ ប្រទេសអ្នកសង្កេតការណ៍រួមមាន : ប្រទេសឥណ្ឌា ប៉ូឡូញ សហព័ន្ធរុស្ស៊ី សិង្ហបុរី ថៃឡង់ដ៍ និងវៀតណាម។ អង្គការ មាន : ធនាគារអភិវឌ្ឍន៍អាស៊ី (**ADB**) សហគមន៍អឺរ៉ុប (**EC**) អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អង្គការអភិវឌ្ឍន៍របស់សហប្រជាជាតិ (**UNDS**) និងធនាគារពិភពលោក។ អង្គការក្រៅរដ្ឋាភិបាលរួមមាន MEDICAM, Silaka, និងអង្គការទស្សនៈពិភពលោកប្រចាំនៅកម្ពុជា។ តំណាងផ្នែកឯកជនមកពីក្រុមការងារផ្នែកច្បាប់ ពន្ធដា និងអភិបាលកិច្ច ក៏បានចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។*

---